ចូរថែរក្សា បរិដ្ឋាន ក្នុងកាលដែលអ្នកថែទាំឡានរបស់អ្នក ។ យកប្រេងម៉ាស៊ីន និងដំរងប្រេងបានប្រើរួចទៅឆ្នៃធ្វើប្រើទៀត បន្ទាប់ពីប្តូរវាម្តងៗ ។ ការចាក់ប្រេងម៉ាស៊ីនទៅលើដី ឬក្នុងប្រឡាយ គឺជាការលើសច្បាប់ ពីព្រោះវាធ្វើឲ្យពុលដល់បរិដ្ឋាន ។ ការយកវាទៅឆ្នៃធ្វើប្រើទៀត គឺជាមធ្យោបាយដ៏ល្អបំផុត ដើម្បីចោលប្រេងម៉ាស៊ីន និងដំរងប្រេងដែលបានប្រើរួច...ហើយវាក៏ងាយផងដែរ!

វាមានមធ្យោបាយពីរយ៉ាងដ៏ងាយស្រួល ដើម្បីយកប្រេងម៉ាស៊ីន និងដំរងប្រេងទៅឆ្នៃធ្វើប្រើទៀត នៅឡុងប៊ីច ។

ដើម្បីឲ្យបានពត៌មានថែមទៀត អំពីការបន្ថយសំរាម និងការឆ្នៃធ្វើប្រើទៀត សូមទូរស័ព្ទទៅខ្សែប្រចាំការនៃការឆ្នៃធ្វើប្រើទៀត នៃទីក្រុងឡុងប៊ីច តាមទូរស័ព្ទលេខ : (562) 570-2876 ។

បានទទួលថវិកាឥតយកសំណងពី គណៈកម ការួបរួមគ្នានូវការចាត់ចែងសំរាម California Integrated Waste Management Board ។

សូន្យសំរាម : ចូរអ្នកធ្វើឲ្យការគានសំរាមសោះកើតឡើង!

ដោយស្របតាមក្រិត្យជនពិការអាមេរិកាំងនៃឆ្នាំ 1990 ។ ពត៌មាននេះគឺមានជាទំរង់ផ្សេងទៀត ដោយទូរស័ព្ទទៅលេខ (562) 570-2850 ឬទូរស័ព្ទទៅលេខTDD# 570-2863 ។

RECYCLE USED MOTOR OIL
CITY OF LONG BEACH

សូមមើល អន្តរបណ្តាញរបស់យើង
www.longbeach-recycles.org

ជួយរក្សាផ្លូវថ្នល់របស់យើង ឲ្យបានស្អាតជានិច្ច

តើអ្នកដឹងឬទេថា ការបោះចោលអ្វីៗ — ដូចជា សំរាម ស្លឹកឈើ អាចម៍សត្វ ប្រេងម៉ាស៊ីន និងទឹករថយន្តផ្សេងៗទៀតទៅក្នុងប្រឡាយ គឺជាការបំពានច្បាប់ សុទ្ធសាត — ពីព្រោះវាធ្វើឲ្យកខ្វក់ទឹកសមុទ្ររបស់យើង ។

ហេតុដូច្នេះហើយ ត្រូវធ្វើការរួមគ្នាដើម្បីរក្សាទឹកសមុទ្ររបស់យើងឲ្យបានស្អាត ដោយមិនបោះចោលសំភារៈអ្វី ទៅក្នុងប្រឡាយ ។ សូមទូរស័ព្ទទៅទីក្រុងឡុងប៊ីឆ តាមលេខ 570-2876 បើអ្នកឃើញរបស់អ្វីធំៗ ឬវត្ថុអ្វីដែលនាំឲ្យគ្រោះថ្នាក់ នៅក្នុងផ្លូវថ្នល់ ឬនៅក្នុងប្រឡាយ ។



នៅពេលប្រេងម៉ាស៊ីនដែលបានប្រើរួច បានចាក់ចោល ទៅក្នុងលូទឹក នោះវាហូរត្រង់ភ្លឹងទៅសមុទ្រ ។

1

កមវិធីឆ្នៃធ្វើប្រើទៀត នៅតាមមូលដ្ឋាន

ប្រេងម៉ាស៊ីន និងដំរងប្រេងបានប្រើរួច នឹងបានប្រមូលតែតាមការស្នើប៉ុណ្ណោះ ។ សូមទូរស័ព្ទទៅលេខ (800) RECYCL2 ឲ្យបានមុនម៉ោង 4 រស្យៀល ដើម្បីស្នើយកប្រដាប់ដាក់ដោយឥតគិតថ្លៃ ឬគ្រោងពេលឲ្យគេមកយកប្រេងម៉ាស៊ីន និងដំរងប្រេងដែលបានប្រើរួច នៅថ្ងៃប្រមូលវត្ថុឆ្នៃធ្វើប្រើទៀត នៅលើកក្រោយទៀត ។ ត្រូវដាក់ប្រេងម៉ាស៊ីន និងដំរងប្រេង ឲ្យឃ្លាតពីរទេះមានកង់ចំងាយពីរហ្វីត (គឺមិនដាក់វានៅក្នុងរទេះទេ) ហើយដាក់វានៅខាងក្រៅលុះត្រាតែបានគ្រោងពេលមក យកតែប៉ុណ្ណោះ ។

ងាយស្រួលដូច 1 - 2 - 3 :

1. សូមពិនិត្យមើលក្រែងលោអ្នកមានរទេះពណ៌ស្វាយ សំរាប់ដាក់វត្ថុឆ្នៃធ្វើទៀត ។ បើសិនជាអ្នកមានការនេះមានន័យថា ទីក្រុងនឹងប្រមូលយកវត្ថុដែលអាចឆ្នៃធ្វើប្រើទៀត នៅតាមលំនៅដ្ឋានរបស់អ្នក ។
2. ទូរស័ព្ទទៅលេខ **(800) RECYCL2** ដើម្បីឲ្យគេយកមកឲ្យនូវប្រដាប់ដាក់ប្រេងម៉ាស៊ីន និងដំរងប្រេងដែលបានប្រើរួច ដោយឥតគិតថ្លៃ ។
3. បន្ទាប់ពីប្រដាប់ដាក់របស់អ្នកពេញហើយ ទូរស័ព្ទទៅ លេខ **(800) RECYCL2** ម្តងទៀត ដើម្បីស្នើឲ្យគេមកយកប្រដាប់ដាក់របស់អ្នកដែលពេញនោះ នៅថ្ងៃប្រមូលសំរាមលើកក្រោយ ។
   សូមដាក់វានៅក្បែរនឹងរទេះពណ៌ស្វាយរបស់អ្នក គឺមិននៅខាងក្នុងឡើយ ។

2

កន្លែងប្រមូល វត្ថុ-ទំលាក់ចោល

បើអ្នកពុំទទួលការបំរើយកវត្ថុទៅឆ្នៃធ្វើប្រើទៀតពីទីក្រុងទេ សូមទូរស័ព្ទទៅលេខ (562) 570-2876 ដើម្បីយកបញ្ជីបញ្ជាក់ទីកន្លែង ដែលអាចយកវត្ថុមកចោលបាន ។ ត្រូវដាក់ប្រេងម៉ាស៊ីន ឬដំរងប្រេងដែលបានប្រើរួច ទៅក្នុងប្រដាប់ដាក់ដែលបិទជិត ហើយយកវាទៅកន្លែងណាមួយដ៏ងាយស្រួល ដែលទីក្រុងឡុងប៊ីច បានបញ្ជាក់ថាជាកន្លែងដែលអាចយកវត្ថុឆ្នៃធ្វើប្រើទៀត ។ អ្នកនឹងទទួលប្រាក់ 16¢ សំរាប់ប្រេងម៉ាស៊ីនមួយហាឡុង ដែលអ្នកយកវាមកឆ្នៃធ្វើប្រើទៀត នៅតាមទីកន្លែងទាំងនោះ ។

ងាយស្រួលដូច 1 - 2 - 3 :

1. បើអ្នកពុំមានមានរទេះពណ៌ស្វាយ សំរាប់ដាក់វត្ថុឆ្នៃធ្វើទៀតទេ ទីក្រុងនឹងមិនអាចប្រមូលយកវត្ថុដែលអាចឆ្នៃធ្វើប្រើទៀត នៅតាមលំនៅដ្ឋានរបស់អ្នក បានឡើយ ។
2. ទូរស័ព្ទទៅលេខ **(562) 570-2876** ដើម្បីឲ្យគេយកមកឲ្យនូវប្រដាប់ដាក់ប្រេងម៉ាស៊ីន និងដំរងប្រេងដែល បានប្រើរួច បើសិនជាត្រូវការ ។
3. នៅពេលប្រដាប់ដាក់របស់អ្នកបានពេញហើយ ទូរស័ព្ទ ទៅ (562) 570-2876 ឬមើលវ៉ុបសៃនៅ www.longbeach-recycles.org សំរាប់ឲ្យ
   ដឹងបញ្ជីនៃទីកន្លែងយកទៅទំលាក់ចោល ដែលស្ថិត នៅជិតកន្លែងអ្នករស់នៅ ។

បានបោះពុម្ពលើក្រដាសឆ្នៃធ្វើប្រើទៀត